**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍**

**រឿងក្ដីរដ្ឋប្បវេណី**

លេខ: ៤៧៥

ចុះថ្ងៃទី ០៦-១០-២០១០

**សាលដីកា**

លេខ: ០៦ ក្រ៥.ប

ចុះថ្ងៃទី ១៧-០២-២០១១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១១

### សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសាលាឧទ្ធរណ៍

- ដើមចោទឈ្មោះ [redacted] **កោសល្យ** និងឈ្មោះ [redacted] **សុខា** មានទីលំនៅ ភូមិស្វាយក្រវ៉ាន់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។

- ចុងចម្លើយឈ្មោះ [redacted] **ជា** និងប្ដីឈ្មោះ [redacted] **បាន** មានទីលំនៅភូមិផ្សារសាមគ្គី សង្កាត់កណ្ដាលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដោយមានលោក [redacted] **ពូង** ជាមេធាវីតំណាងដោយអាណត្តិ ។

### អង្គហេតុ និងចំណុចវិវាទ

**១- ខ្លឹមសារដែលទាមទារដោយដើមចោទៈ**

- ដើមចោទប្ដឹងទាមទារប្រាក់ចំនួន ១២០០០ ដុល្លា ( មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ដូចមាននៅក្នុងកិច្ចសន្យាខ្ចីប្រាក់ កាលពីថ្ងៃទី ០១-១២-២០០៨ ពីចុងចម្លើយ ការប្រាក់ ៦០០ដុល្លា ( ប្រាំមួយរយដុល្លាអាមេរិក) ក្នុងមួយខែ រហូតដល់សងប្រាក់គ្រប់ចំនួន និងសុំឱ្យរឹបអូសផ្ទះ និងដីដែលដាក់បញ្ចាំ ។

- សុំទាមទារការខាតបង់ និងការយឺតយ៉ាវចំនួន ៤០០០ដុល្លា ( បួនពាន់ដុល្លាអាមេរិក) ។

- សុំឱ្យភាគីចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ។

Scanned with CamScanner

**២- ការអះអាងរបស់ភាគី**

- ភាគីដើមចោទឈ្មោះ [redacted] **សុខា** និងប្តីឈ្មោះ [redacted] **កោសល្យ** បានថ្លែងការណ៍ថា ដំបូងឈ្មោះ [redacted] **ផា** បានទៅខ្ចីប្រាក់ពីបងស្រីរបស់ខ្លួនឈ្មោះ [redacted] **សុខជា** បន្ទាប់មកឈ្មោះ [redacted] **សុខជា** ប្រាប់ឱ្យមកជួបខ្លួន ទើបឈ្មោះ [redacted] ផា បានមកជួបខ្លួនហើយបានព្រមព្រៀងធ្វើកិច្ចសន្យាខ្ចីប្រាក់ចំនួន ១២០០០ដុល្លា ( មួយម៉ឺនពីរពាន់ដុល្លាដុល្លាអាមេរិក) ដោយព្រមព្រៀងឱ្យការប្រាក់ ៦០០ដុល្លា ( ប្រាំមួយរយដុល្លាអាមេរិក) ក្នុង១ខែ ហើយក៏បានចុះកិច្ចសន្យានៅថ្ងៃទី ០១-១២-២០០៨ ដោយមានសាក្សីមេភូមិ មេឃុំដឹងឮទៀតផង ក្រោយពីភាគីចុងចម្លើយបានទទួលប្រាក់ពីខ្លួនហើយ ភាគីចុងចម្លើយមិនបានអនុវត្តតាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ០១-១២-២០០៨ ដោយមិនបង់ការប្រាក់ និងប្រាក់ដើមមកឱ្យខ្លួនតាមកិច្ចសន្យាខ្ចីប្រាក់រហូតមកដល់សព្វថ្ងៃនេះ ។ សំណូមពរសុំទាមទារប្រាក់ដើមចំនួន ១២០០០ដុល្លា ( មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ការប្រាក់ ៦០០ដុល្លា ( ប្រាំមួយរយដុល្លាអាមេរិក) ក្នុង១ខែ និងទាមទារការយឺតយ៉ាវចំនួន ៤០០០ ដុល្លា (បួនពាន់ដុល្លាអាមេរិក) ហើយបើភាគីចុងចម្លើយគ្មានប្រាក់សងទេ គឺស៊ុំរឹបអូសផ្ទះ និងដីដែលបានដាក់បញ្ចាំ

- ភាគីចុងចម្លើយឈ្មោះ [redacted] **ផា** ដែលមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិបានថ្លែងការណ៍ថា កូនក្តីរបស់ខ្លួនពិតជាបានខ្ចីប្រាក់ពីភាគីដើមចោទចំនួន ១២០០០ ដុល្លា ( មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ហើយព្រមព្រៀងបង់ការប្រាក់ ៦០០ដុល្លា (ប្រាំមួយរយដុល្លាអាមេរិក) ក្នុង១ខែ មាននៅក្នុងកិច្ចសន្យាចងការប្រាក់ឱ្យទៅដើមចោទក្នុង ១ថ្ងៃ ២០ ដុល្លាអាមេរិក សរុបទាំងអស់ចំនួន ១៥២០ដុល្លា (មួយពាន់ប្រាំរយម្ភៃដុល្លាអាមេរិក) រួចហើយ ដូច្នេះក្នុងរឿងក្តីនេះខ្លួនទទួលស្គាល់ប្រាក់ដើម ១២០០០ដុល្លា (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ហើយសុំឱ្យគិតការប្រាក់ទៅតាមច្បាប់កំណត់ ដោយគិតចាប់ពីថ្ងៃទី ១៤-០២-២០០៩ ។

**៣- ចំណុចវិវាទ**

- ភាគីដើមចោទបានអះអាងថា ភាគីចុងចម្លើយមិនបានបង់ការប្រាក់ និងប្រាក់ដើមមកឱ្យខ្លួនតាមកិច្ចសន្យាទេ តែភាគីចុងចម្លើយបានអះអាងថា ខ្លួនបានបង់ការប្រាក់ក្នុង ១ថ្ងៃ ២០ដុល្លា សរុបចំនួន ១៥២០ ដុល្លា ( មួយពាន់ប្រាំរយម្ភៃដុល្លាអាមេរិក) ឱ្យទៅដើមចោទហើយ ។

**ការអះអាងរបស់ដើមចោទ:** ដើមចោទឈ្មោះ [redacted] **សុខា** បានថ្លែងការណ៍ថា នៅសាលាដំបូងខេត្តកំពង់ស្ពឺមេធាវីការពារក្តីឱ្យគាត់បានកាត់ការប្រាក់ចំនួន ៧២ថ្ងៃចោល ខ្លួនក៏យល់ព្រម ប៉ុន្តែគឺគិតត្រឹមថ្ងៃទី ១៤-០២-២០០៩ ។ សំណូមពរសុំឱ្យតុលាការតំកល់សាលក្រមរបស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការដដែល ។

**ការអះអាងរបស់ចុងចម្លើយ:** ចុងចម្លើយឈ្មោះ [redacted] **ផា** បានថ្លែងការណ៍ថា ប្រាក់ដែលខ្លួនបង់ជាថ្ងៃក្នុង ១ ខែ ៦០០ USD ( ប្រាំមួយរយដុល្លាអាមេរិក) គឺខ្លួនសុំ ក្នុងថ្ងៃ ២០ USD ( ម្ភៃដុល្លាអាមេរិក) សរុប

ក្នុង១ខែ ៦០០ USD (ប្រាំមួយរយដុល្លាអាមេរិក) ។ ខ្លួនទទួលស្គាល់ជំពាក់ប្រាក់ដើមចោទ ១២០០០ ដុល្លា (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ប្រាកដមែន តែសុំសងក្នុង ១ខែ ៥០ ដុល្លា (ហាសិបដុល្លាអាមេរិក) ។

## សំអាងហេតុ

## យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី ២៦-០៥-២០១០ របស់ចុងចម្លើយឈ្មោះ [redacted] ផា ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីសាលឧទ្ធរណ៍ អាចធ្វើការទាញហេតុផលបាន ។

២- ចុងចម្លើយឈ្មោះ [redacted] ផា ទទួលស្គាល់ការទាមទាររបស់ដើមចោទឈ្មោះ [redacted] សុខា នូវទឹកប្រាក់ដែលខ្លួនបានខ្ចីចំនួន ១២០០០$ (មួយម៉ឺនពាន់ពីរដុល្លាអាមេរិក) និងការប្រាក់ចំនួន ៦០០$ ក្នុងមួយខែ តាមកិច្ចសន្យា ចុះថ្ងៃទី ០១-១២-២០០៨ ប្រាកដមែន ប៉ុន្តែដំណាក់កាលទាញហេតុផលនៅជាន់សាលាឧទ្ធរណ៍ ថាខ្លួនបានសងការប្រាក់ ២ខែ ២០ថ្ងៃ ស្មើនឹង ១៥២០$ ឱ្យទៅដើមចោទរួចហើយដើមចោទក៏ទទួលស្គាល់ថាបានទទួលដែរ នៅពេលទាញហេតុផលសាលាឧទ្ធរណ៍ ។ តាមរយៈបណ្តឹងឧទ្ធរណ៍របស់ភាគីចុងចម្លើយ ស្នើសុំសងក្នុង ១ខែ ៥០$ ចំនុចនេះសាលាដំបូងបានលើកសំអាងហេតុ បញ្ជាក់ជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពទាំងស្រុងលើសំអាងហេតុនេះ សាលាឧទ្ធរណ៍មិនលើកយកសំអាងហេតុដដែលមកបញ្ជាក់ជូនជាថ្មីទៀតទេ ហើយការស្នើសុំនេះ សាលាឧទ្ធរណ៍មិនពិចារណាឡើយ ។

៣- សាលក្រមរដ្ឋប្បវេណីលេខ ០២ (ឆ) ចុះថ្ងៃទី ១២-០៥-២០១០ របស់សាលាដំបូងខេត្តកំពង់ស្ពឺ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គួរតំកល់ទុកជាបានការ លើកលែងតែប្រាក់ដើម និងការប្រាក់គប្បីសំរេចជាថ្មី ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ច្រានចោលបណ្តឹងឧទ្ធរណ៍របស់ចុងចម្លើយ

២- តំកល់សាលក្រមដើមរបស់សាលាដំបូងខេត្តកំពង់ស្ពឺតែត្រូវកែប្រែលើប្រាក់ដើម និងការប្រាក់ សំរេចថា បង្គាប់ឱ្យ [redacted] ផា និងឈ្មោះ [redacted] បាន សងប្រាក់ដើមចំនួន ១០៤៨០$ (មួយម៉ឺនបួនរយប៉ែតសិបដុល្លាអាមេរិក) ឱ្យទៅដើមចោទឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] កុសល្យ និងការប្រាក់ ៥% ក្នុង១ឆ្នាំ គិតពីថ្ងៃទី ០១-១២-២០០៨ រហូតសងគ្រប់ ។ ក្រៅពីនេះរក្សាទុកដដែល ។

៣- ប្រាក់ប្រដាប់ក្តីជាបន្ទុកចុងចម្លើយ ។

Scanned with CamScanner

{475} 06-10-2010 VSK

៤- សាលដីកាប្រកាសជាសាធារណៈ ថ្ងៃទី ១៧-០២-២០១១ បើកផ្លូវប្តឹងសាទុក្ខក្នុងអំឡុងពេល ១ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

| ក្រឡាបញ្ជី | ចៅក្រុមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|

ហត្ថលេខា: [redacted]

---

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 11 ខែ 12 ឆ្នាំ ២០១១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]